**សេចក្តីប្រកាសព័ត៌មាន**

**ទាក់ទង: នៅភ្នំពេញ លោក ប៊ូ សារឿន** (855) 23-217-301
sbou@worldbank.org
**នៅវ៉ាស៊ីនតោន: លោកស្រី អេលីហ្សាប៊ែត មាលី** (202) 458 4475
emealey@worldbank.org

# សេចក្តីថ្លែងការណ៍របស់ធនាគារពិភពលោកចំពោះការប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបញ្ចប់គម្រោងគ្រប់គ្រងដីធ្លីនិងរដ្ឋបាល

**ភ្នំពេញ ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០០៩ - បន្ទាប់ពីការសម្រេចចិត្តមួយដែលបានធ្វើឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ៤ ខែ កញ្ញា កន្លងទៅ ចំពោះការបញ្ចប់ការផ្តល់ហិរញ្ញវត្ថុរបស់ធនាគារពិភពលោកដល់គម្រោងគ្រប់គ្រង ដីធ្លី និង រដ្ឋបាល (LMAP) នាយកធនាគារពិភពលោកប្រចាំតំបន់អាស៊ីអាគ្នេយ៍ លោកស្រី អាណែត ឌីកសុន បានចេញសេចក្តីថ្លែងការណ៍ដូចតទៅ:**

"សុវត្ថិភាពដីធ្លី និងដំណោះស្រាយប្រកបដោយយុត្តិធម៌ និងតម្លាភាព ដើម្បីដោះស្រាយជំលោះដីធ្លី និងការផ្លាស់ប្តូរទីលំនៅថ្មី គឺជាបញ្ហាប្រឈមក្នុងចំណោមបញ្ហាប្រឈមដ៏ធំផ្សេងៗទៀតដែលកម្ពុជាកំពុងជួបប្រទះ ។ ប្រជាជនដែលគ្មានដី ឬគ្មានកម្មសិទ្ធិដីធ្លី ទំនងជាមានបញ្ហាខាងជីវភាព (ក្រីក្រ) និងអាចស្ថិតក្នុងស្ថានភាពក្រីក្របន្តទៀត ។

ដោយសារហេតុផលទាំងនេះហើយ ចាប់តាំងពីឆ្នាំ ២០០២ ធនាគារពិភពលោកបានធ្វើការយ៉ាងសកម្មជាមួយរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍នានា រួមទាំងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីរៀបចំដាក់ឱ្យមានប្រព័ន្ធទំនើប និងទូលំទូលាយមួយសម្រាប់រដ្ឋបាលដីធ្លី ។ គំរោងនេះបានចេញប័ណ្ណកម្មសិទ្ធិដីធ្លីជាង ១,១ លាន សន្លឹក ភាគច្រើនបានផ្តល់ជូនដល់ប្រជាជនក្រីក្រនៅជនបទ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែតម្លៃដីឡើងថ្លៃនាពេលកន្លងមកថ្មីនេះ ដែលមានប្រមាណជាមធ្យម ៣០ ភាគរយ បាននាំទៅរកបញ្ហានានា ដូចជា ជម្លោះដីធ្លី បញ្ហាសំណងជំងឺចិត្ត ដំណើរការបណ្តេញចេញ និងបញ្ហាការផ្លាស់ប្តូរទីលំនៅថ្មី ។

ជាផ្នែកមួយនៃការបន្តការពិភាក្សាជាមួយរដ្ឋាភិបាលចំពោះបញ្ហាប្រឈមដែលកើតឡើងនេះ ធនាគារពិភពលោកបានធ្វើការសិក្សាពិនិត្យមើលឡើងវិញដើម្បីស្វែងរកថាតើគម្រោងLMAPនេះ នៅតែសម្រេចបានទៅតាមគោលបំណងដែលគម្រោងបានរៀបចំឡើងឬយ៉ាងណា ក្នុងកាលៈទេសៈដែលមានការកើនឡើងយ៉ាងលឿននៃការផ្លាស់ប្តូរបរិយាកាសក្នុងវិស័យដីធ្លីនេះ ។

ការសិក្សានេះបានរកឃើញថា គម្រោង LMAP សម្រេចបានជោគជ័យចំពោះការផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាជននៅជនបទ ប៉ុន្តែមិនសម្រេចបានទៅតាមគោលដៅនៅទីក្រុងដែលជាកន្លែងមានបញ្ហាកើតឡើងនោះទេ។ ហេតុផលទាំងនេះ ដោយសារមួយផ្នែកមកពីការពន្យាពេល ឬ ការខ្វះខាតនៃការអនុវត្តសកម្មភាពរបស់គម្រោងមួយចំនួន ។ ទោះបីជាធាតុដើមនៃការរៀបចំគម្រោងនេះមានដំណោះស្រាយចំរុះដើម្បីដោះស្រាយបញ្ហាដីធ្លីក្តី គម្រោង LMAP បានផ្តោតយ៉ាងសំខាន់ទៅលើផ្នែកដែលអាចទទួលបានជោគជ័យៈ ការផ្តល់កម្មសិទ្ធិដីធ្លីនៅជនបទ និងការកសាងសមត្ថភាពសម្រាប់រដ្ឋបាលដីធ្លី ដើម្បីចុះបញ្ជី និង ចេញប័ណ្ណកម្មសិទ្ធិដីធ្លី និង ការអនុវត្តគោលនយោបាយ។

យើងបានដាក់ជូនលទ្ធផលដែលរកឃើញនេះទៅរាជរដ្ឋាភិបាលហើយ ប៉ុន្តែមិនអាចឈានទៅដល់កិច្ចព្រមព្រៀងគ្នាមួយ ថាតើគោលនយោបាយសុវត្ថភាពសង្គម និង បរិស្ថានសម្រាប់គម្រោង LMAP គួរត្រូវបានអនុវត្តចំពោះជម្លោះមួយចំនួននៅទីក្រុងឬយ៉ាងណានោះទេ ។ សម្រាប់ធនាគារពិភពលោក ការអនុវត្តគោលនយោបាយសុវត្ថភាពទាំងនេះមានសារៈសំខាន់ណាស់ ។ ទោះជាយ៉ាងណាក៏ដោយ យើងមានការរីករាយចំពោះសេចក្តីប្រកាសរបស់រដ្ឋាភិបាលលើការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការបន្តកំណែទំរង់ក្នុងវិស័យដីធ្លី និង ធ្វើការងារមួយចំនួនទៀត ដើម្បីកែលំអគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់ការផ្លាស់ប្តូរទីលំនៅថ្មីដែលវានឹងឆ្លើយតបទៅនឹងសទ្ទិសញ្ញាអន្តរជាតិនានា។

យើងនៅតែប្តេជ្ញាចិត្តដើម្បីធ្វើការជាមួយរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍នានា តាមរយៈក្រុមការងារបច្ចេកទេសស្តីពីដីធ្លី ក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីសុវត្ថភាពកម្មសិទ្ធិដីធ្លី កាត់បន្ថយភាពក្រីក្រ និងការលើកកំពស់ឱកាសសេដ្ឋកិច្ចដល់ប្រជាជនកម្ពុជាទាំងមូល”។

###